**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :......៣០៩........ ប.ទ.ប្រក

ភ្នំពេញ, ថ្ងៃទី២០ ខែ តុលា ឆ្នាំ ២០០៣

# ប្រកាស

## ស្តីពីការ បង្កើតគណៈកម្មការរៀបចំទីតាំងថ្មី នៃអាគារប្រៃសណីយ៍ និងទូរគមនាគមន៍ឃាវិត

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួលនិងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ / បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-យោងតាមការងារចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១ :** ត្រូវបានបង្កើតគណៈកម្មការមួយ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលមានមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១-ឯកឧត្តម **ឡុង ទាន់ហន** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម **ឆូច ហេង** | អគ្គនាយក ប.ទ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣-លោក | ញាណរា ស្រស់ | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៤-លោក | កែវ ទុន្លរិន | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៥-លោក | ទេព ម៉ុន្ថា | ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក | ព្រាប សុរិទ្ធិ | ប្រធាននាយកដ្ឋានប្រៃសណីយ៍ | សមាជិក |
| ៧-លោក | លី សំអាន | ប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ | សមាជិក |
| ៨-លោក | ឡៅ សារឿន | អនុប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស | សមាជិក |
| ៩-លោក | គីម ឈន | ប្រធានមន្ទីរ ប.ទ ខេត្តស្វាយរៀង | សមាជិក |
| ១០-លោក | លី ភាយម្ធុទ្ធិ | ប្រធានការិយាល័យសំណង់ | សមាជិក |
| ១១-លោក | អ៊ឹម ទុន្លា | ប្រធានមជ្ឈមណ្ឌលបញ្ជូនស៊ីញ៉ាល់ | សមាជិក |
| ១២-លោក | តុល ញ៉ក់ | អនុប្រធានមជ្ឈមណ្ឌលបញ្ជូនស៊ីញ៉ាល់ | សមាជិក |

**ប្រការ២** : គណៈកម្មការនេះ មានភារៈកិច្ច សិក្សារកទីតាំងថ្មី សំរាប់សាងសង់អាគារ ប្រៃសណីយ៍ និង ទូរគមនាគមន៍ បាវិត ដោយរៀបចំបែបបទ លើកគំរោងថវិកា សំរាប់ចំណាយលើការ រុះរើ សំភារៈបរិក្ខាបច្ចេកទេស ពីកន្លែងចាស់មកកន្លែងថ្មី និងការសាងសង់អាគារថ្មី ទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយមានលក្ខណៈសមស្រប សំរាប់ធ្វើអាជីវកម្ម សេវាកម្មលើ វិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

**ប្រការ៣** : គណៈកម្មការនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ **ឯកឧត្តមប្រធាន** ។

**ប្រការ៤** : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** : អគ្គនាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋាន ប.ទ--អធិការដ្ឋាន-នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ-នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស-មន្ទីរ ប.ទ ខេត្តស្វាយរៀង និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍ តាមខ្លឹមសារ នៃ ប្រកាសនេះ ។

**ប្រការ៦** : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស្ទួរ. ឃុន

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
-សាលាខេត្តស្វាយរៀង
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៥ "ដើម្បីអនុវត្តន៍"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ